# ចំណាប់អារម្មណ៍អំពីការអភិវឌ្ឍន៍ម៉ាក្រូសេដ្ឋកិច្ច

**ថ្លែងដោយ លោក ចន នែមស៍ (John Nelmes)**

**តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅកម្ពុជា**

**ជូនសមុខអោយដៃគូរអភិវឌ្ឍន៍នានា**

**នៅ**

## វេទិកាសហប្រតិបត្តិការ និង អភិវឌ្ឍន៍កម្ពុជា

ភ្នំពេញ ថ្ងៃទី 4 ខែ ធ្នូ ឆ្នាំ 2008

**ឯកឧត្តម លោកជំទាវ លោក លោកស្រី**

ខ្ញុំសូមអរគុណ ដែលត្រូវផ្តល់ឱកាសអោយចូលរួមក្នុងវេទិកាសហប្រតិបត្តិការ និង អភិវឌ្ឍន៍កម្ពុជានា (CDCF) ឆ្នាំនេះ ហើយខ្ញុំមានកិត្តិយសក្នុងការថ្លែងចំណាប់អារម្មណ៏អំពីការអភិវឌ្ឍន៏ម៉ាក្រូសេដ្ឋកិច្ច ជូសមុខ អោយដៃគូរ អភិវឌ្ឍន៏នានា របស់រាជរដ្ឋាភិបាលកម្ពុជា។

**ការអភិវឌ្ឍន៍ម៉ាក្រូសេដ្ឋកិច្ចពេលកន្លងទៅថ្មីៗនេះ**

អ្វីៗច្រើនបានកើតឡើងនៅក្នុងផ្នែកម៉ាក្រូសេដ្ឋកិច្ច ចាប់តាំងពីពេលដែលដៃគូរអភិវឌ្ឍន៏នានា និងរាជរដ្ឋាភិបាលបានជួបគ្នានៅឯវេទិកាសហប្រតិបត្តិការ និងអភិវឌ្ឍន៏កម្ពុជានៅខែ មិថុនា ឆ្នាំ 2007។ សេដ្ឋកិច្ចបានបន្តកំណើនពីរខ្ទង់ជាឯកទត្តៈកម្មគួរអោយសរសើរនៅឆ្នាំកន្លងទៅ សំរេចបានប្រមាណ 10¼ ភាគរយ ហើយកំលាំងចលករនេះ បានអូសទាញបន្តរហូតដល់ពាក់កណ្តាលទីមួយ នៃឆ្នាំ 2008 : កំណើននៃការនាំចេញសំលៀកបំពាក់ និង ទេសចរណ៏ ទោះបីជាមានភាពបង្អង់ល្បឿនខ្លះ បាននៅតែខ្លាំងក្លាបង្គួរ ផលិតផលកសិកម្មបានអនុគ្រោះ ហើយវិនិយោគបរទេសគួបជាមួយនឹងកំណើនយ៉ាងខ្ពស់ណាស់នៃការអោយខ្ចីនៃធនាគារពាណិជ្ជ ជំរុញសកម្មភាពសំណង់យ៉ាងលឿន និងការឡើងនៃតំលៃផ្ទះសម្បែង។

នៅពេលដែលពាក់កណ្តាលទីមួយ នៃឆ្នាំ 2008 បានរំកិលទៅមុខ ក៏រិតខ្ពស់នៃសេចក្តីត្រូវការក្នុងសេដ្ឋកិច្ចបានដាក់សំពាធកាន់តែធ្ងន់ឡើងៗ លើថ្លៃទំនិញនានាសំរាប់អ្នកប្រើប្រាស់នៅកម្ពុជា។ គួបជាមួយការកើនឡើងនៃតំលៃប្រេង និង ម្ហូបអាហារអន្តរជាតិយ៉ាងរហ័សនិងខ្ពស់ណាស់ និងការឡើងថ្លៃនៃតំលៃផលិតផលនាំចូល

ដោយសារតែការធ្លាក់ចុះនៃតំលៃប្រាក់រៀលនិងប្រាក់ដុល្លា ប្រៀបធៀបជាមួយរូបិយប័ណ្ណរបស់ប្រទេសនានាដែលជាដៃគូរពាណិជ្ជកម្មចំបងៗរបស់កម្ពុជា អតិផរណាបានកើនឡើងដល់កំពូល គឺ 26 ភាគរយ នៅពាក់កណ្តាល ឆ្នាំ 2008 ។

ចាប់តាំងពីពាក់កណ្តាលឆ្នាំមក បរិដ្ឋានម៉ាក្រូសេដ្ឋកិច្ចបានប្រែប្រឡះយ៉ាងរហ័ស ហើយជាពិសេសក្នុងកំឡុងប៉ុន្មានខែកន្លងមកនេះ ដោយសារកម្ពុជាបាននិងកំពុងចាប់ផ្តើមទទួលនូវឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុពិភពលោក និង ការបន្ថយល្បឿននៃកំណើនសេដ្ឋកិច្ចពិភពលោកដែលជាប់ទាក់ទងគ្នានោះ ។ ការនាំចេញសំលៀកបំពាក់ និងការមកដល់នៃទេសចរណ៍កំពុងបន្ថយល្បឿន ឆ្លុះបញ្ចាំងអោយឃើញមិនត្រឹមតែការចុះថយយ៉ាងលឿននៃសេដ្ឋកិច្ចរបស់ដៃគូរពាណិជ្ជកម្មចំបងៗរបស់កម្ពុជាទេ ថែមទាំងសំពាធលើភាពប្រកួតប្រជែងរបស់កម្ពុជាដោយសារតែអតិផរណាក្នុងស្រុកខ្ពស់ និងការឡើងថ្លៃនៃប្រាក់រៀលនិងប្រាក់ដុល្លា ។ សកម្មភាពសំណង់ និងការវិនិយោគបរទេសកំពុងតែបន្ថយល្បឿន ឆ្លុះបញ្ចាំងពីភាពលក្ខខ័ណ្ឌខ្សត់ជាងមុននៃសាច់ប្រាក់ងាយស្រួល (Liquidity) ទាំងលើពិភពលោក និង ក្នុងស្រុក ។ គិតជារួមកត្តាទាំងនេះត្រូវរំពឹងថានាំមកនូវភាពថមថយនៃកំណើនមកប្រហែល 6½ ភាគរយក្នុងឆ្នាំ 2008 ។

ចំពោះកំនត់សំគាល់ជាវិជ្ជមានមួយ អតិផរណាទូទៅបានចាប់ផ្តើមធ្លាក់ចុះ សមស្របតាមការថយចុះថ្មីៗនេះនៃតំលៃប្រេង និងការកើនឡើងនៃតំលៃប្រាក់រៀលនិងប្រាក់ដុល្លា ។ ជាមួយនឹងកំណើនដែលមានភាពថមថយ សំពាធអតិផរណាដែលបង្កដោយតំរូវការក្នុងស្រុក គួរតែថយចុះ ហើយអតិផរណាអាចត្រូវរំពឹងទុកថាធ្លាក់ចុះមកប្រហែល 15½ ភាគរយនៅចុងឆ្នាំ 2008 ។

## បញ្ហាគន្លឹះនានានៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

សឹងតែមិនចាំបាច់និយាយ បរិដ្ឋានសំរាប់ការកសាងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចគឺមានភាពស្មុគ្រស្មាញ ។ រាជរដ្ឋាភិបាលត្រូវប្រឈមនឹងសំពាធសេចក្តីតំរូវការក្នុងស្រុក ការប៉ះទង្គិចពីខាងក្រៅយ៉ាងធំចំពោះតំលៃទំនិញ និង អត្រាប្តូរប្រាក់ ដែលប្រែក្រឡាស់បញ្ច្រាសទិសនៅប្រហែលពាក់កណ្តាលឆ្នាំ ហើយថ្មីៗបំផុតនេះគឺភាពយ៉ាប់យឺនយ៉ាងរហ័ស នៃតំរូវការក្រៅស្រុក និងលក្ខខ័ណ្ឌហិរញ្ញប្បទាន ។

ពេញមួយឆ្នាំ 2008 កិច្ចខំប្រឹងប្រែងធ្វើអោយមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ត្រូវបានគាំទ្រដោយជំហរគោលនយោបាយសារពើពន្ធប្រកបដោយស្ថិរភាព រួមទាំងក្នុងរយៈពេលបោះឆ្នោត ហើយរាជរដ្ឋាភិបាលកម្ពុជាសក្តិសម ទទួលការកោតសរសើរចំពោះកិច្ចខំប្រឹងប្រែងនេះ ។ ចំណូលរដ្ឋាភិបាលបានកើនឡើងយ៉ាងខ្លាំងក្នុងឆ្នាំ 2008 ហើយត្រូវគ្រោងថានឹងបានដល់ 12½ ភាគរយ នៃផលទុនជាតិសរុប ដោយសារវិធានការជាចំបងគឺការបន្តការកែលំអរដ្ឋបាលចំណូល ។ ចំណាយត្រូវបានថែរក្សាអោយសមស្របជាមួយគោលដៅថវិកា

ហើយកត្តាទាំងអស់នេះរួមបញ្ចូលគ្នាសង្ឃឹមថានាំមកនូវការថយចុះនៃឱនភាពថវិកាទូទៅរបស់រដ្ឋាភិបាល (ដោយមិនរួមបញ្ចូលជំនួយឥតសំណង) មកប្រហែល 1¾ ភាគរយ ក្នុងឆ្នាំ 2008 នៅពេលដែលប្រាក់បញ្ញើរបស់រដ្ឋាភិបាលនៅប្រព័ន្ធធនាគារកើនឡើង។

ថ្មីៗនេះទៀត គោលនយោបាយរូបិយវត្ថុ ក៏បានជួយដើរតួក្នុងតួនាទីរក្សាស្ថិរភាព។ ក្នុងកំឡុងពាក់កណ្តាលទីមួយ នៃឆ្នាំ 2008 លំហូរនៃមូលធនបរទេសយ៉ាងខ្លាំង និងកំណើនប្រាក់បញ្ញើក្នុងស្រុក បានធ្វើអោយមានកំណើនឥណទានឯកជនដែលឈានដល់កំរិតកំពូល គឺលើសពី 100 ភាគរយក្នុងខែមិថុនា ប្រៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន ហើយនេះបានជំរុញសំពាធអតិផរណា។ ធនាគារជាតិនៃកម្ពុជាបានឆ្លើយតបយ៉ាងសមស្របដោយបង្កើនទ្វេឡើងនូវទុនបំរុងកាតព្វកិច្ចសំរាប់ប្រាក់បញ្ញើរដល់ 16 ភាគរយ។ ដៃគូរអភិវឌ្ឍន៍ក៏បានកោតសរសើរចំពោះធនាគារជាតិកម្ពុជា ដែលបានបង្កើនមូលធនអប្បរមាកាតព្វកិច្ចរបស់ធនាគារនានា ដែលនឹងជួយដាក់ប្រព័ន្ធធនាគារលើគ្រឹះដ៏រឹងមាំ។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ និងដោយសារលំហូរមូលធនពីខាងក្រៅមានភាពយឺត កំណើនឥណទានបានបង្អន់ល្បឿនដែលជួយបន្ថយសំពាធអតិផរណា។

ឆ្ពោះទៅមុខ ការប្រមើលមើលសេដ្ឋកិច្ចត្រូវសង្ឃឹមថានៅតែមានភាពប្រឈមក្នុងដំណាក់កាលជិត។ ការបន្ថយល្បឿននៃសេដ្ឋកិច្ចពិភពលោក ត្រូវគិតថាមានឥទ្ធិពលអាក្រក់ដល់សសរគ្រឹះសំខាន់ៗនៃសេដ្ឋកិច្ចកម្ពុជា ហើយកំណើនត្រូវគ្រោងថានឹងមានប្រមាណ 4¾ ភាគរយ ក្នុងឆ្នាំ 2009។ អតិផរណាគួរតែបន្តថយចុះមកត្រឹមលេខមួយខ្ទង់ក្នុងឆ្នាំ 2009 ដោយសារតំលៃទំនិញស្រុតចុះ និងសំពាធសេចក្តីត្រូវការថមថយ។

ច្បាស់លាស់ណាស់ ភាពប្រឈមនានាចំពោះសេដ្ឋកិច្ចគឺខ្លាំងក្លា ហើយជាការពិត ហានិភ័យគឺជាភាពប្រឈមទាំងនោះដែលអាចកាន់តែមានកំរិតខ្លាំងក្លាឡើងៗ មុនពេលវាស្ងប់ទៅវិញ។ ស្របតាមការប្រមើលមើលក្នុងដំណាក់កាលជិត និងហានិភ័យទាំងនោះ អាទិភាពជាគន្លឹះមួយនឹងត្រូវធ្វើអោយបាន គឺគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលអនុញ្ញាតអោយមានការបន្ធូរបន្ថយឥទ្ធិពលនៃការប៉ះទង្គិចពីខាងក្រៅដែលបក់បោកមកលើប្រទេសកម្ពុជា។ ឥឡូវនេះជាពេលដែលត្រូវបង្កើនល្បឿនកំណែទំរង់នានា ដែលពង្រឹងមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចកម្ពុជា គឺមិនត្រូវងាកចេញពីការងារដែលកាន់តែលំបាកនោះទេ។ នៅពេលនេះ ត្រូវផ្តោតលើការកែលំអបរិដ្ឋានវិនិយោគ រួមទាំងការប្រឆាំងនឹងអំពើពុករលួយ និងពង្រឹងអភិបាលកិច្ច ដើម្បីបន្ធូរបន្ថយឥទ្ធិពលនៃការថយចុះនៃការវិនិយោគបរទេសផ្ទាល់លើពិភពលោក ដោះស្រាយការបាត់បង់ភាពប្រកួតប្រជែងក្នុងតំបន់ ដូចជាតាមរយៈជំរុញការរីកចំរើនក្នុងការងារសំរួលពាណិជ្ជកម្ម ពង្រឹងភាពរឹងប៉ឹងរបស់ធនាគារដោយបន្តការកែលំអបទបញ្ញានានា និងការត្រួតពិនិត្យ និងបង្កើនល្បឿនក្នុងការសំរេចគោលដៅអភិវឌ្ឍន៍ក្នុងស្រុកនានា ដូចជាចំណាយលើហេដ្ឋារចនាសម្ព័ន្ធសំរាប់តំបន់ជនបទ និងផ្នែកកសិកម្ម។ ទទួល

បានមកវិញនូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការអនុវត្តកំណែទំរង់រចនាសម្ព័ន្ធជាគន្លឹះនានា ដើម្បីជួយពង្រីកមូលដ្ឋានផលិតកម្មរបស់កម្ពុជា និងលុបបំបាត់ចោលកត្តារាំងស្ទះដល់កំណើន គឺជាធាតុផ្សំសំខាន់ៗទាំងអស់សំរាប់ទប់ទល់ នឹងកំណើនយឺតក្នុងតំណាក់កាលជិត និងដើម្បីបន្តភាពជឿនលឿនក្នុងការកាត់បន្ថយភាពក្រីក្រហើយឈាន ទៅសំរេចគោលដៅអភិវឌ្ឍន៍សហសវត្សរបស់កម្ពុជា។

ដៃគូរអភិវឌ្ឍន៍ស្វាគមន៍ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើអោយមានការជឿនលឿនបន្តទៀតក្នុងការអនុវត្តកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរួមទាំងប្រាក់ឧបត្ថមផ្អែកលើគុណសម្បត្តិ (MBPI)។ ឆ្ពោះទៅដំណាក់កាលទីពីរ តំរូវអោយមានជាបន្ទាន់ការបង្កើនល្បឿននៃ ភាពជឿនលឿនលើចំណុចសំខាន់ជាគន្លឹះនានានៃកំណែទំរង់រួមមានៈ (i) ពង្រឹងសមាហរណកម្ម និងវិសហមជ្ឈការនៃថវិកា (ii) អនុវត្តប្រព័ន្ធគណនេយ្យនិងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលគាំទ្រការតាមដាន និងកត់ត្រាចំណាយជាពិសេសចំណាយមូលធន និងចំណាយកាត់បន្ថយភាពក្រីក្រ (iii) កែលំអគណនេយ្យភាពតាមរយៈតំលាភាព ឧទាហរណ៍ ឆ្លងតាមការបញ្ចេញអោយឃើញការធ្វើសវនកម្មពីខាងក្រៅប្រចាំឆ្នាំ និងចំណូលផ្សេងៗបានមកពីវិស័យនិស្សារណកម្ម--វិស័យទាញយកផលពីធម្មជាតិ (Extractive Industries)។ វិធានការណ៍ទាំងនេះ នឹងលើកដំកើងជាបន្ថែមទៀតចំពោះភាពជឿជាក់នៃថវិកានិងពង្រឹងទំនុកចិត្តដែលថាប្រាក់កាសសារធារណៈកំពុងត្រូវបានប្រើប្រាស់ប្រកប ដោយផលិតភាព។

ក្នុងបរិបទនេះ ដៃគូរអភិវឌ្ឍន៍នានាសូមលើកឡើងនូវបញ្ហាមួយចំនួន ដែលទស្សនៈរបស់រាជរដ្ឋាភិបាលចំពោះបញ្ហាទាំងនេះនឹងត្រូវស្វាគមន៍ជាទីបំផុត :

- គោលនយោបាយសារពើពន្ធបន្ធូរបន្ថយទប់ទល់នឹងខួបសេដ្ឋកិច្ច (Countercyclical) ក្នុងឆ្នាំ 2009 នឹងជួយសំរាលការប៉ះទង្គិចនៃកំណើនដែលយឺត។ ចំណូលរដ្ឋាភិបាល ជាភាគរយនៃ GDP នឹងប្រហែលជាថយចុះបន្តិច ដោយសារកំណើននៃការនាំចូលថយល្បឿន ហើយករណីនេះជារឿងសមស្របដោយសារតែវាធ្វើការដូចជាស្ថេរករ (Stabilizer) ស្វ័យប្រវត្តិ។ យ៉ាងណាមិញ ទោះបីលទ្ធផលដ៏គួរអោយស្វាគមន៍ក្នុងឆ្នាំ 2008 ការអនុវត្តចំណូលនៅតែទាបជាងចំណូលក្នុងបណ្តាប្រទេសដែលមានប្រាក់ចំណូលតិចនានា ហេតុដូច្នោះហើយ ការផ្តាំផ្តែងនានាចំពោះសមិទ្ធិផលដែលទទួលបានយ៉ាងលំបាកពីរដ្ឋបាលចំណូល ត្រូវតែជៀសវាង។ ដៃគូរអភិវឌ្ឍន៍គាំទ្រ ធ្វើការខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងបន្ថែមទៀតនូវរដ្ឋបាលចំណូល និងបន្តចាប់យកការទទួលខុសត្រូវកាន់តែច្រើនឡើងៗ ក្នុងការធ្វើហិរញ្ញប្បទានដល់តំរូវការចំណាយដែលចាំបាច់នានា។ តើ

ជំហានអ្វីខ្លះដែលរដ្ឋាភិបាលត្រូវអនុវត្ត ដើម្បីធានាអោយមានការកែលំអជាបន្ត ចំពោះការប្រមូលចំណូលប្រកបដោយជោគជ័យ ?

- ទោះបីជាចំណាយរបស់រដ្ឋាភិបាលខ្ពស់ជាងមុន នឹងជួយទប់ទល់នឹងកំណើនយឺត វាត្រូវអោយផ្តល់អាទិភាពយ៉ាងប្រុងប្រយ័ត្ន ហើយផ្តោតអោយចំ។ ចំណាយចរន្តគួរផ្តល់អាទិភាពដល់ចំណាយសង្គមជួយអ្នកក្រីក្រ និងដោះស្រាយភាពងាយរងគ្រោះក្នុងដំណាក់កាលជិត រួមទាំងសំណាញ់សន្តិសុខសង្គម ដែលមានគោលដៅច្បាស់លាស់សំរាប់អ្នកដែលងាយរងគ្រោះបំផុត។ ត្រូវអោយមានការដោះស្រាយបញ្ហាប្រាក់បៀវត្សរ៍ទាបរបស់រដ្ឋាភិបាល ទោះបីជាចំណាយសំរាប់ប្រាក់បៀវត្សរ៍ខ្ពស់ជាងមុន រួមទាំងចំណាយប្រាក់បៀវត្សរ៍ដែលទាក់ទងនិងការពង្រីកសមាជិករាជរដ្ឋាភិបាលក៏ដោយ គឺត្រូវតែផ្សារភ្ជាប់ និងកំណែទំរង់សេវារដ្ឋការគ្រប់ជ្រុងជ្រោយមួយ ដែលលើកកំពស់ប្រសិទ្ធិភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈ (ជាបញ្ហាមួយដែលនឹងត្រូវពិភាក្សាក្នុងវគ្គក្រោយនៃវេទិកា សហប្រតិបត្តិការនិងអភិវឌ្ឍន៍កម្ពុជា)។ ចំណាយផ្នែកយោធាគួរផ្តោតទៅលើតំរូវការចាំបាច់នានា ដើម្បីជៀសវាងការធ្វើអោយចង្អៀតដល់ ការចំណាយចាំបាច់ដ៏ទៃទៀតដែលបង្ក អោយឱនភាពរីកធំដ៏មិនចាំបាច់ ហើយអាចធ្វើអោយខ្សោយដល់ជំហរក្រៅប្រទេស។ ចំណាយមូលធនទៅលើគំរោងហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់នានា នឹងមិនត្រឹមតែជំរុញកំណើនក្នុងតំណាក់កាលជិតប៉ុណ្ណោះទេ នៅពេលជាមួយគ្នានោះ វាថែមទាំងលើកកំពស់សក្តានុពលកំណើននៃសេដ្ឋកិច្ចក្នុងតំណាក់កាលមធ្យម និងទាក់ទាញវិនិយោគបរទេសផ្ទាល់។ តើថវិកា និងក្របខ័ណ្ឌចំណាយដំណាក់កាលមធ្យម (MTEF) អាចធានាថាទាំងចំណាយចរន្តនិងចំណាយមូលធនផ្តល់អាទិភាពចំពោះវិស័យសំខាន់ៗទាំងនោះយ៉ាងដូចម្តេច?

- ចុងបំផុត បទពិសោធន៍បង្ហាញពីសារៈសំខាន់នៃតំលាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងចំណូលពីវិស័យនិស្សារណកម្ម (Extractive Industries) ទាំងការដោះស្រាយភាពប្រឈមផ្នែកម៉ាក្រូសេដ្ឋកិច្ចដែលវិស័យនោះនាំមក និងការទទួលបានចំណូលច្រើនបំផុត ដែលវិស័យនេះផ្តល់អោយ។ ដៃគូរអភិវឌ្ឍន៍ស្វាគមន៍ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងផ្នែកតំលាភាព និងគណនេយ្យភាព។ ដោយទទួលស្គាល់នូវភាពមិនច្បាស់លាស់ជាបន្តទៀតនៃធនធានក្រោមសមុទ្រនិងក្រោមដី និងទទួលដឹងថាសមត្ថភាពនៅមានកំរិតនាពេលបច្ចុប្បន្ន អ្វីទៅគឺជាផែនការជាក់ស្តែងរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើនតំលាភាព និងគណនេយ្យភាពក្នុងវិស័យនេះ?

ជាចុងបញ្ចប់ សូមអនុញ្ញាតិអោយខ្ញុំបញ្ជាក់ម្តងទៀតអំពីអំណរគុណចំពោះការផ្តល់ឱកាសចូលរួមក្នុងវេទិកាសហប្រតិបត្តិការ និងអភិវឌ្ឍន៍កម្ពុជាថ្ងៃនេះ។ នៅពេលដែលបរិដ្ឋានសេដ្ឋកិច្ចក្នុងតំណាក់កាលជិត មើលទៅកាន់តែស្មុគ្រស្មាញ យើងជឿជាក់ថារាជរដ្ឋាភិបាលកម្ពុជាអាចដោះស្រាយភាពប្រឈមទាំងនេះ។ ច្បាស់ណាស់ ឆ្លងផុតពីដំណាក់កាលជិត ការប្រមើលមើលនៃសេដ្ឋកិច្ចកម្ពុជា នៅតែត្រចះត្រចង់ ដោយសារតែការប្តេជ្ញាចិត្តជាបន្ត ក្នុងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចយ៉ាងប្រុងប្រយ័ត្ន។ ជួសមុខអោយដៃគូរអភិវឌ្ឍន៍នានា ខ្ញុំសូមជូនពររាជរដ្ឋាភិបាល អោយទទួលបានជោគជ័យក្នុង ការខំព្យាយាមនានារបស់ខ្លួន។